ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខ័ណ្ឌកម្មវិធីសិក្សា

## ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់
## ផ្នែកគ្រប់គ្រងអប់រំ

វិទ្យាស្ថានជាតិអប់រំ ឆ្នាំ២០២០

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ បានបន្តដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយផ្តល់អាទិភាពលើវិស័យអប់រំដើម្បីអភិវឌ្ឍមូលធនមនុស្ស និងពង្រឹងសមត្ថភាព ប្រសិទ្ធភាព និងភាពជឿទុកចិត្តដល់បុគ្គលិកអប់រំ ក្នុងការផ្តល់និងគាំទ្រសេវាអប់រំ ឱ្យឆ្លើយតបទៅនឹងនិន្នាការអប់រំសតវត្សរ៍ទី២១។

ដើម្បីរួមចំណែកក្នុងការសម្រេចឱ្យបានយុទ្ធសាស្ត្រចតុកោណនេះ ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ដោយបានដាក់ចេញនូវគោលនយោបាយអប់រំចំនួន ២ គឺ (១) ធានាការអប់រំមានគុណភាព ប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង (២) ធានាភាពស័ក្តិសិទ្ធនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការដាក់ចេញនូវកម្មវិធីកំណែទម្រង់ចំនួន១៥ចំណុច ដោយឈរលើសសរស្តម្ភចំនួន ០៥ គឺ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) ការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល (៣) ការធ្វើអធិការកិច្ចគ្រប់ជ្រុងជ្រោយ (៤) ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និង (៥) ការធ្វើកំណែទម្រង់ឧត្តមសិក្សា។

ក្នុងការឆ្លើយតបទៅនឹងគោលនយោបាយអប់រំខាងលើ វិទ្យាស្ថានជាតិអប់រំ ដែលមានបេសកកម្មបណ្តុះបណ្តាល និងវិក្រឹត្យការគ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ចអប់រំ អ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ បានរៀបចំក្របខណ្ឌកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមយ៉ាងមុតមាំថា ក្របខណ្ឌកម្មវិធីសិក្សានេះ នឹងផ្តល់ឱ្យ អ្នកសិក្សាទទួលបាននូវចំណេះ ជំនាញ និងឥរិយាបថ តាមរយៈការសិក្សាស្រាវជ្រាវលើមុខវិជ្ជារួម មុខវិជ្ជាឯកទេស មុខវិជ្ជាជម្រើស និងការសរសេរនិក្ខេបបទបញ្ចប់ការសិក្សា។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះស្នាដៃដ៏ល្អរបស់ក្រុមការងារដែលបានខិតខំអភិវឌ្ឍក្របខ័ណ្ឌកម្មវិធីបណ្តុះបណ្តាលនេះឡើង។

ថ្ងៃ ចន្ទ ៣ កើត ខែ មិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# គណៈកម្មការ

## I. គណៈកម្មការគ្រប់គ្រង

| | | | |
|---|---|---|---|
| ១. ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | រដ្ឋមន្ត្រី | ប្រធាន |
| ២. ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម | លាង សេងហាក់ | អនុរដ្ឋលេខាធិការ | សមាជិក |
| ៤. ឯកឧត្តម | ងួន មាស | អគ្គនាយកនៃអគ្គ.រដ្ឋបាល&ហិរញ្ញវត្ថុ | សមាជិក |
| ៥. លោកបណ្ឌិត | ឌី សមស៊ីដេត | អគ្គនាយករងនៃអគ្គនា.ដ្ឋានអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត | ឌី ខាំបូលី | អគ្គនាយករងនៃអគ្គ.គននិងផែនការ | សមាជិក |
| ៧. លោកជំទាវបណ្ឌិត | ឃួន វិច្ឆិកា | អគ្គនាយករងនៃអគ្គនា.ដ្ឋានអប់រំ | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | នាយកវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩. លោក | ង៉ោ ប៉េងឡុង | ប្រធាននា.ប.ប និងវិក្រឹតការ | សមាជិក |
| ១០. លោក | ណែប ស៊ីនថៃ | អ្នកសម្របសម្រួលគម្រោង | សមាជិក |

## II. ក្រុមការងារបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាលក្រោយឧត្តម និងការបណ្តុះបណ្តាលបន្ត

| | | | |
|---|---|---|---|
| ១. លោកបណ្ឌិត | នូវ វីរ៉ា | នាយករងវិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២. លោកបណ្ឌិត | សុខ សូត្រ | ព្រឹទ្ធបុរសមហាវិទ្យាល័យអប់រំនៃស.ភ.ភ.ព | អនុប្រធាន |
| ៣. លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | អនុប្រធាននា.បណ្តុះបណ្តាលនិងវិក្រឹតការ | អនុប្រធាន |
| ៤. លោក | ឃិន ស៊ីដា | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៥. លោកបណ្ឌិត | អ៊ែ ស៊ុនហ៊ាង | នាយកមជ្ឈ.តំបន់អាស៊ីអាគ្នេយ៍.បច្ចេកទេស | សមាជិក |
| ៦. លោក | មាក សុភា | ប្រ.ការិយាល័យនៃនា.ធានាគុណភាពអប់រំ | សមាជិក |
| ៧. លោក | ម៉ន មុនិន្ទ | ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ | សមាជិក |
| ៨. លោក | ចាប រតនា | អនុប្រ.ដេប៉ាតឺម៉ង់គ្រប់គ្រងនិងផែនការ | សមាជិក |
| ៩. លោកបណ្ឌិត | ឈាង សង្វាត | គ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០. លោកបណ្ឌិត | ម៉ម សុជាតិ | សាស្ត្រាចារ្យស.ភ.ភ.ព | សមាជិក |
| ១១. លោកបណ្ឌិត | សុត វិសាល | សាស្ត្រាចារ្យស.ភ.ភ.ព | សមាជិក |
| ១២. លោកស្រីបណ្ឌិត | ស្វាយ សោមា | សាស្ត្រាចារ្យស.ភ.ភ.ព | សមាជិក |
| ១៣. កញ្ញា | ហ៊ា ស៊ីរី | ប្រធានការិ.នៃវិ.បច្ចេកវិទ្យាកំពង់ស្ពឺ និងជាសមាជិក លេខាធិការដ្ឋានអភិវឌ្ឍ.គរុកោសល្យ | សមាជិក |
| ១៤. លោក | ម៉ែន សំណាង | មន្ត្រីលេខាធិការដ្ឋាននៃអគ្គ.អប់រំ និងជាសមាជិក លេខាធិការដ្ឋានអភិវឌ្ឍ.គរុកោសល្យ | សមាជិក |

# មាតិកា


បុព្វកថា ..... i

គណៈកម្មការ ..... ii

មាតិកា ..... iii

១. សេចក្តីផ្តើម ..... 1

២. ចក្ខុវិស័យនៃក្របខ័ណ្ឌកម្មវិធីសិក្សា ..... 2

៣. បេសកកម្មនៃក្របខ័ណ្ឌកម្មវិធីសិក្សា ..... 2

៤. គោលបំណងនៃក្របខ័ណ្ឌកម្មវិធីសិក្សា ..... 2

៥. រយៈពេល និងកាលវិភាគនៃក្របខ័ណ្ឌកម្មវិធីសិក្សា ..... 2

៦. ការកំណត់ក្រេឌីតសិក្សា ..... 3

៧. ប្រព័ន្ធចំណាត់ថ្នាក់ពិន្ទុ GPA ..... 3

៨. ការសរសេរនិក្ខេបបទ ការធ្វើសិក្ខាសាលា បាឋកថា និងសកម្មភាពផ្សេងៗ ..... 4

៩. សុចរិតភាពនៃការសិក្សា ..... 4

១០. រចនាសម្ព័ន្ធនៃក្របខ័ណ្ឌកម្មវិធីសិក្សា ..... 5

១១. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា ..... 7

១២. ការវាយតម្លៃការបណ្តុះបណ្តាល ..... 14

ឯកសារយោង ..... 16

## ១. សេចក្តីផ្តើម

និន្នាការអភិវឌ្ឍន៍នាពេលបច្ចុប្បន្ន ទាំងក្នុងតំបន់និងពិភពលោក មានគោលបំណងរួមមួយគឺត្រូវសម្រេចឱ្យបាននូវគោលដៅនៃការអភិវឌ្ឍប្រកបដោយចីរភាព ដែលក្នុងនោះគោលដៅទី៤ (SDG-4) គឺជាកត្តាចម្បងក្នុងការសម្រេចឱ្យបាននូវគោលដៅខាងលើ។

ឆ្លើយតបនឹងនិន្នាការនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវ៖ (១) យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៤ ដោយផ្តល់អាទិភាពលើវិស័យអប់រំ (២) គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មដោយផ្តោតទៅលើការកសាងសមត្ថភាពនិងការអភិវឌ្ឍមូលធនមនុស្ស និង(៣) គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០១៤ ដោយផ្តោតលើការប្រែក្លាយបុគ្គលិកអប់រំឱ្យមានសមត្ថភាពប្រសិទ្ធភាពនិងភាពជឿទុកចិត្តក្នុងការផ្តល់និងគាំទ្រសេវាអប់រំ ដែលជាផ្នែកមួយក្នុងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងស្ថាប័ន។

ដើម្បីរួមចំណែកក្នុងការសម្រេចបានយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល ក្រសួងអប់រំ យុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ ដោយបានដាក់ចេញនូវគោលនយោបាយអប់រំចំនួន២គឺ (១) ធានាការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និង (២) ធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រងរបស់មន្ត្រីអប់រំគ្រប់លំដាប់ថ្នាក់ តាមរយៈការដាក់ចេញនូវកម្មវិធីកំណែទម្រង់ចំនួន១៥ចំណុច ឈរលើសសរស្តម្ភចំនួន៥៖ (១) ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២) ការកែលម្អកម្មវិធីសិក្សានិងសៀវភៅសិក្សាគោល (៣) ការធ្វើអធិការកិច្ចគ្រប់ជ្រុងជ្រោយ (៤) ការពង្រឹងវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និង (៥) ការធ្វើកំណែទម្រង់ឧត្តមសិក្សា។ ផែនការយុទ្ធសាស្រ្តវិស័យអប់រំ ឆ្នាំ២០១៩-២០២៣ ក៏បានគូសរំលេចពីបញ្ហាប្រឈមមួយចំនួននៅក្នុងប្រព័ន្ធអប់រំ ក្នុងនោះបញ្ហាប្រឈមជាក់ស្តែងមួយ គឺពាក់ព័ន្ធទៅនឹងសមត្ថភាពដឹកនាំ និងគ្រប់គ្រងអប់រំ។ ដោះស្រាយបញ្ហាប្រឈមនេះ ពិសេសដើម្បីពង្រឹងសមត្ថភាពបុគ្គលិកអប់រំ ទាំងចំណេះដឹង និងជំនាញ ក្រសួងក៏បានអភិវឌ្ឍគោលនយោបាយស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ (CPD) របស់បុគ្គលិកអប់រំ និងក្របខ័ណ្ឌគន្លងអាជីពគ្រូបង្រៀន។

ក្នុងការអនុវត្តគោលនយោបាយខាងលើ និងដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងសមត្ថភាពគ្រប់គ្រងនិងដឹកនាំអប់រំ ឱ្យឆ្លើយតបទៅនឹងតម្រូវការសតវត្សរ៍ទី២១ វិទ្យាស្ថានជាតិអប់រំ ដែលមានបេសកកម្មបណ្តុះបណ្តាល និងវិក្រឹត្យការគ្រូបង្រៀន អ្នកគ្រប់គ្រងអប់រំ មន្ត្រីអធិការកិច្ចអប់រំ អ្នកធ្វើផែនការអប់រំ និងអ្នកស្រាវជ្រាវវិទ្យាសាស្រ្តបច្ចេកទេសអប់រំ បាននិងកំពុងរៀបចំក្របខណ្ឌកម្មវិធីសិក្សាសម្រាប់បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ តាមរូបភាពអាហារូបករណ៍ និងការបង់ថ្លៃសេវាសិក្សា។

ក្របខ័ណ្ឌកម្មវិធីសិក្សានេះ ផ្តល់ឱ្យអ្នកសិក្សាទទួលបាននូវចំណេះ ជំនាញ និងឥរិយាបថ តាមរយៈការសិក្សាស្រាវជ្រាវលើមុខវិជ្ជារួម មុខវិជ្ជាឯកទេស មុខវិជ្ជាជម្រើស និងការសរសេរនិក្ខេបបទ

បញ្ចប់ការសិក្សា។

## ២. ចក្ខុវិស័យនៃក្របខ័ណ្ឌកម្មវិធីសិក្សា

ចក្ខុវិស័យនៃក្របខ័ណ្ឌកម្មវិធីសិក្សានេះ គឺអភិវឌ្ឍសមត្ថភាពមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ឱ្យមានចំណេះដឹង ជំនាញ និងបំណិន ព្រមទាំងមានកិរិយាមាយាទ គោរពវិន័យ និងសាមគ្គីភាពល្អ ដើម្បីចូលរួមផ្តល់សេវាអប់រំប្រកបដោយគុណភាព បរិយាបន្ន និងសមធម៌ ស្របតាមបរិបទនៃការអប់រំសតវត្សរ៍ទី២១ ក្នុងការអភិវឌ្ឍសង្គមពុទ្ធិ និងវិបុលភាព។

## ៣. បេសកកម្មនៃក្របខ័ណ្ឌកម្មវិធីសិក្សា

បេសកកម្មនៃក្របខ័ណ្ឌកម្មវិធីសិក្សានេះ គឺបណ្តុះបណ្តាលមន្ត្រីគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ ឱ្យមានសមត្ថភាព ចំណេះដឹង និងជំនាញលើ៖ (១) និន្នាការនៃការអប់រំកម្រិតជាតិ តំបន់ និងអន្តរជាតិ (២) ប្រព័ន្ធអប់រំនៅកម្ពុជា (៣) ផែនការ និងគោលនយោបាយនានាពាក់ព័ន្ធការងារអប់រំ (៤) ការវិភាគ និងការរៀបចំផែនការអភិវឌ្ឍវិស័យអប់រំ (៥) ការដោះស្រាយហានីភ័យនានាដែលពាក់ព័ន្ធនឹងវិស័យអប់រំ (៦) ការសិក្សាស្រាវជ្រាវអប់រំ ស្ថិតិអប់រំ និងការសរសេរនិក្ខេបបទ និង (៧) ការធ្វើអភិបាលកិច្ចល្អ តាមរយៈការផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែង និងការផ្តល់សេវាសិក្សាប្រកបដោយគុណភាពជាមួយសាស្ត្រាចារ្យដែលមានចំណេះដឹង និងសមត្ថភាព។

## ៤. គោលបំណងនៃក្របខ័ណ្ឌកម្មវិធីសិក្សា

ក្របខ័ណ្ឌកម្មវិធីសិក្សានេះ ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈមន្ត្រីអប់រំទាំងផ្នែកចំណេះដឹង និងជំនាញថ្មីៗ ក្នុងការបំពេញតួនាទីជាមន្ត្រីរដ្ឋបាលអប់រំ អ្នកធ្វើផែនការកម្មអប់រំ អ្នកដឹកនាំនិងគ្រប់គ្រងអប់រំគ្រប់លំដាប់ថ្នាក់ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ និងប្រសិទ្ធភាព សម្រាប់ធ្វើការអភិវឌ្ឍធនធានមនុស្ស និងសេដ្ឋកិច្ចសង្គម។

## ៥. រយៈពេល និងកាលវិភាគនៃក្របខ័ណ្ឌកម្មវិធីសិក្សា

ក្របខ័ណ្ឌកម្មវិធីសិក្សានេះ មានរយៈពេល០២ឆ្នាំ និងត្រូវចែកចេញជា០២ផ្នែកធំៗគឺ ការសិក្សាស្រាវជ្រាវក្នុងថ្នាក់មានរយៈពេល១៨ខែ និងការសរសេរនិក្ខេបបទមានរយៈពេល០៦ខែ។ រីឯកាលវិភាគសិក្សាវិញ ក៏ត្រូវបានបែងចែកជា០២ប្រភេទ សម្រាប់អ្នកសិក្សាជ្រើសរើសដែរ គឺការសិក្សាក្នុងសប្តាហ៍ (ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ) និងការសិក្សាចុងសប្តាហ៍ (ពីថ្ងៃសៅរ៍ ដល់ថ្ងៃអាទិត្យ)។

## ៦. ការកំណត់ក្រេឌីតសិក្សា

ក្របខ័ណ្ឌនៃកម្មវិធីសិក្សានេះ មានចំនួន៤៨ក្រេឌីត និងតម្រូវឱ្យអ្នកសិក្សាចំណាយពេល ០២ឆ្នាំ ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ។ ក្នុងរយៈពេល០២ឆ្នាំនេះ អ្នកសិក្សាត្រូវធ្វើការសិក្សា និងស្រាវជ្រាវលើមុខវិជ្ជាចំនួន ១៤ (ស្មើនឹង៤២ ក្រេឌីត) និងសរសេរនិក្ខេបបទដែលមានចំនួន ០៦ក្រេឌីតបន្ថែមទៀត។ ដើម្បីទទួលបាន០១ក្រេឌីត អ្នកសិក្សាត្រូវចំណាយពេល១៥ម៉ោង ដោយសិក្សាផ្ទាល់ជាមួយសាស្ត្រាចារ្យក្នុងថ្នាក់ ឬ៣០ម៉ោងដោយអនុវត្តក្នុងមន្ទីរពិសោធន៍ ឬ៤៥ម៉ោង ដោយធ្វើស្វ័យសិក្សាខ្លួនឯង។

សម្រាប់ឆ្នាំទី១ អ្នកសិក្សាត្រូវរៀនចំនួន ១០មុខវិជ្ជា ស្មើនឹង៣០ក្រេឌីត។ ដូច្នេះ អ្នកសិក្សាត្រូវរៀនចំនួន ០៥មុខវិជ្ជានៅឆមាសទី១ និង០៥មុខវិជ្ជាទៀតនៅឆមាសទី២។ នៅក្នុងឆ្នាំទី២ អ្នកសិក្សាត្រូវរៀនចំនួន ០៤មុខវិជ្ជាបន្ថែមទៀត (ស្មើនឹង១២ក្រេឌីត) ហើយត្រូវសរសេរនិក្ខេបបទដែលមានតម្លៃស្មើនឹង០៦ក្រេឌីត។

ក្នុងអំឡុងពេលឆមាសទី១ (ក្នុងឆ្នាំទី២) អ្នកសិក្សាត្រូវធ្វើការសម្រេចចិត្តជ្រើសរើសគ្រូណែនាំបង្គោលម្នាក់ និងគ្រូណែនាំរងម្នាក់ ដើម្បីជួយណែនាំក្នុងការសរសេរនិក្ខេបបទ។ ក្នុងឆមាសទី២ ឆ្នាំទី២ អ្នកសិក្សាត្រូវកំណត់ប្រធានបទ និងសរសេរគម្រោងស្រាវជ្រាវ ដោយមានការពិគ្រោះយោបល់ជាមួយគ្រូណែនាំបង្គោល និងគ្រូណែនាំរងជាប្រចាំ។

## ៧. ប្រព័ន្ធចំណាត់ថ្នាក់ពិន្ទុ GPA

**អ្នកសិក្សាទាំងអស់ ត្រូវធ្វើការប្រឡងលើគ្រប់មុខវិជ្ជាដែលបានរៀបចំដោយផ្ទាល់ពីសាស្ត្រាចារ្យដែលបង្រៀនមុខវិជ្ជាទាំងនោះ។ វិទ្យាស្ថានជាតិអប់រំកំណត់ថា** អ្នកសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ត្រូវទទួលបានមធ្យមភាគពិន្ទុសរុបយ៉ាងតិចបំផុតត្រឹម ២.៥០ (ក្នុងប្រព័ន្ធ ៤.០០) ឬនិទ្ទេស C+ ទើបអាចផ្តល់ជូន ឬបញ្ជាក់ជូនសញ្ញាបត្របាន។ ខាងក្រោមនេះ គឺជាប្រព័ន្ធដាក់ពិន្ទុ និងការផ្តល់និទ្ទេស។

$$GPA = \frac{\sum(P \cdot C)}{\sum C}$$

រូបមន្តក្នុងការគណនារកមធ្យមពិន្ទុនិទ្ទេសគឺ មធ្យមភាគពិន្ទុនិទ្ទេស ស្មើនឹងផលបូកនៃផលគុណរវាងពិន្ទុនិទ្ទេស (P) គុណនឹងតម្លៃក្រេឌីត (C) ចែកនឹងផលបូកនៃចំនួនក្រេឌីតគ្រប់មុខវិជ្ជា។

| ពិន្ទុតាមកម្រិត ឬពិន្ទុនិទ្ទេស | សមាសភាគភាគរយ ឬ ថ្នាក់ពិន្ទុ | សញ្ញាពិន្ទុជាអក្សរ ឬថ្នាក់និទ្ទេស | ការបរិយាយ |
|---|---|---|---|
| ៤.០០ | ៨៥-១០០ | A | ល្អប្រសើរ |
| ៣.៥០ | ៨០-៨៤ | B+ | ល្អណាស់ |
| ៣.០០ | ៧០-៧៩ | B | ល្អ |
| ២.៥០ | ៦៥-៦៩ | C+ | ល្អបង្គួរ |
| ២.០០ | ៥០-៦៤ | C | មធ្យម |
| ១.៥០ | ៤៥-៤៩ | D+ | ខ្សោយ |
| ១.០០ | ៤០-៤៤ | D | ខ្សោយណាស់ |
| ០.០០ | ០-៣៩ | F | ធ្លាក់ |

## ៨. ការសរសេរនិក្ខេបបទ ការធ្វើសិក្ខាសាលា បាឋកថា និងសកម្មភាពផ្សេងៗ

**ការសរសេរនិក្ខេបបទ៖** អ្នកសិក្សាតម្រូវឱ្យចុះប្រមូលទិន្នន័យដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សា និងតម្រូវឱ្យធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវតាមដំណាក់កាលដែលកំណត់ដោយក្រុមប្រឹក្សាបច្ចេកទេសទទួលបន្ទុកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំរបស់វិទ្យាស្ថានជាតិអប់រំ។ និក្ខេបបទត្រូវមានចំនួនកំណត់យ៉ាងតិច ៦០ទំព័រ ដោយមិនគិតពីឧបសម្ព័ន្ធ និងឯកសារយោង។

**សិក្ខាសាលាឬបាឋកថា៖** អ្នកសិក្សាតម្រូវឱ្យចូលរួមសិក្ខាសាលា ឬបាឋកថាកម្រិតគ្រឹះស្ថានសិក្សា ឬកម្រិតជាតិ ឬអន្តរជាតិ យ៉ាងតិច ០១ដងក្នុងវគ្គសិក្សា។

## ៩. សុចរិតភាពនៃការសិក្សា

អ្នកសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ត្រូវបង្ហាញនូវសុចរិតភាពនៃការសិក្សារបស់ខ្លួនឱ្យបានខ្ជាប់ខ្ជួន ចាប់តាំងពីពេលចូលរៀនរហូតដល់ចុងបញ្ចប់នៃការសិក្សា។ ក្នុងន័យនេះ អ្នកសិក្សា មិនត្រូវដកស្រង់គំនិត សរសេរ ឬចម្លងស្នាដៃផ្សេងៗ របស់អ្នកដទៃមកធ្វើជាគំនិត ជាស្នាដៃ ឬជាកម្មសិទ្ធិរបស់ខ្លួនឡើយ បើគ្មានការបញ្ជាក់ពីប្រភពច្បាស់លាស់នៃឯកសារយោង ឬឯកសារពិគ្រោះ។ បើពុំនោះទេ នឹងត្រូវប្រឈមមុខចំពោះក្រុមប្រឹក្សាបច្ចេកទេសទទួលបន្ទុកថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំរបស់វិទ្យាស្ថានជាតិអប់រំ តាមរយៈការទទួលពិន័យ ការដាក់ឱ្យរៀនត្រួតថ្នាក់ ឬរៀនមុខវិជ្ជានោះឡើងវិញ ឬបើធ្ងន់ធ្ងរជាងនេះ នឹងត្រូវលុបឈ្មោះចេញពីបញ្ជីឈ្មោះនិស្សិត។

## ១០. រចនាសម្ព័ន្ធនៃក្របខ័ណ្ឌកម្មវិធីសិក្សា

### ១០.១. លក្ខណៈសម្បត្តិដើម្បីទទួលសញ្ញាបត្រ

ក្របខ័ណ្ឌនៃកម្មវិធីសិក្សានេះ មាន ៤៨ក្រេឌីត ដែលក្នុងនោះរួមមាន៖

ក. មុខវិជ្ជារួម៖ ត្រូវបានរៀបចំឡើង ដើម្បីកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំទាក់ទងនឹងការងារអប់រំ និងដើម្បីអភិវឌ្ឍជំនាញដល់អ្នកសិក្សាក្នុងការសិក្សាស្រាវជ្រាវ ដែលមានចំនួន១៥ក្រេឌីត និងត្រូវសិក្សាចំនួន ០៥មុខវិជ្ជា។

ខ. មុខវិជ្ជាឯកទេស៖ មានគោលបំណងពង្រឹងជំនាញឯកទេសដល់អ្នកសិក្សា ដែលពាក់ព័ន្ធនឹងការងារគ្រប់គ្រងអប់រំ ដែលមានចំនួន ២១ក្រេឌីត និងត្រូវសិក្សាចំនួន ០៧មុខវិជ្ជា។

គ. មុខវិជ្ជាជ្រើសរើស៖ មានគោលបំណងធ្វើឱ្យអ្នកសិក្សា មានចំណេះដឹងទូលំទូលាយ និងមានជំនាញពាក់ព័ន្ធផ្សេងទៀត ដែលមានចំនួន ០៦ក្រេឌីត និងត្រូវសិក្សាចំនួន ០២មុខវិជ្ជា។

ឃ. និក្ខេបបទ៖ ពេលបញ្ចប់ការសិក្សា អ្នកសិក្សា ត្រូវសរសេរនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ដែលមានចំនួន ០៦ក្រេឌីត ក្នុងគោលបំណងពង្រឹងជំនាញរបស់អ្នកសិក្សាឱ្យមានសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវលើប្រធានបទជាក់លាក់ណាមួយ។

### ១០.២. មុខវិជ្ជាសិក្សា

| **កម្មវិធីសិក្សា** | **លេខកូដ** | **អាទិភាព** | **ក្រេឌីត** |
|---|---|---|---|
| **I. មុខវិជ្ជារួម** | | | |
| ១. ក្រមសីលធម៌នៃភាពជាអ្នកដឹកនាំការងារអប់រំ | MEA 510 | ចាំបាច់ | ៣ |
| ២. ចិត្តវិទ្យាអប់រំ | MEA 511 | ចាំបាច់ | ៣ |
| ៣. សង្គមវិទ្យាអប់រំ | MEA 512 | ចាំបាច់ | ៣ |
| ៤. មូលដ្ឋានគ្រឹះនៃស្ថិតិក្នុងវិស័យអប់រំ | MEA 513 | ចាំបាច់ | ៣ |
| ៥. វិធីសាស្ត្រស្រាវជ្រាវអប់រំ | MEA 514 | ចាំបាច់ | ៣ |
| | | សរុប | **១៥** |

| | | | |
|---|---|---|---|
| **II. មុខវិជ្ជាឯកទេស** | | | |
| ១. បរិបទនៃសង្គមក្នុងការអប់រំ | MEA 520 | ចាំបាច់ | ៣ |
| ២. រដ្ឋបាលអប់រំ | MEA 521 | ចាំបាច់ | ៣ |
| ៣. បច្ចេកវិទ្យាក្នុងការគ្រប់គ្រង និងការរៀននិងបង្រៀន | MEA 522 | ចាំបាច់ | ៣ |
| ៤. ការអភិវឌ្ឍកម្មវិធីសិក្សា | MEA 523 | ចាំបាច់ | ៣ |
| ៥. ការគ្រប់គ្រងធនធានថវិកា និងសម្ភារូបវន្តនៃការអប់រំ | MEA 524 | ចាំបាច់ | ៣ |
| ៦. ការគ្រប់គ្រងធនធានមនុស្ស | MEA 525 | ចាំបាច់ | ៣ |
| ៧. ការតាមដាន និងការវាយតម្លៃអប់រំ | MEA 526 | ចាំបាច់ | ៣ |
| សរុប | | | **២១** |
| **III. មុខវិជ្ជាជ្រើសរើស (ជ្រើសរើស ០២មុខវិជ្ជា ក្នុងចំណោម ០៥មុខវិជ្ជា)**<br>**បញ្ជាក់៖ តាមការចាំបាច់ វិទ្យាស្ថានជាតិអប់រំ រក្សាសិទ្ធិក្នុងការដាក់មុខវិជ្ជាជ្រើសរើសទាំង០២មុខនេះ សម្រាប់ឱ្យនិស្សិតសិក្សា។** | | | |
| ១. ការអប់រំនៅកម្ពុជា | MEA 530 | ជម្រើស | ៣ |
| ២. ការគ្រប់គ្រងសាលារៀន និងការគ្រប់គ្រងការបំពេញការងារក្នុងសាលា | MEA 531 | ជម្រើស | ៣ |
| ៣. ការសិក្សាជំនាញសរសេរភាសាអង់គ្លេសកម្រិតខ្ពស់ | MEA 532 | ជម្រើស | ៣ |
| ៤. ការគ្រប់គ្រងអប់រំនៅគ្រឹះស្ថានសិក្សាឯកជន | MEA 533 | ជម្រើស | ៣ |
| ៥. ការគ្រប់គ្រងនិងដឹកនាំភាពផ្លាស់ប្តូរ ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការពង្រឹងបណ្តាញ | MEA 534 | ជម្រើស | ៣ |
| សរុប | | | **៦** |
| **IV. និក្ខេបបទ (ការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់)** | | | |
| ១. និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ | MEA 599 | ចាំបាច់ | ៦ |
| សរុបរួម | | | ៤៨ |

### ១០.៣. ការកំណត់ និងការវាយតម្លៃ ដើម្បីផ្ទេរក្រេឌីតសិក្សា

- អ្នកសិក្សាអាចផ្ទេរចំនួនក្រេឌីត ឬសិក្សាបន្ថែមដើម្បីអាចទទួលសញ្ញាបត្របាន។
- អ្នកសិក្សា ដែលបានសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដែលមានមុខវិជ្ជាសមមូលទៅនឹងមុខវិជ្ជាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ អាចដាក់ពាក្យសុំផ្ទេរក្រេឌីតបាន។

- ការផ្ទេរក្រេឌីតអាចផ្តល់ឱ្យអ្នកសិក្សាណាដែលបានដាក់ពាក្យសុំតែប៉ុណ្ណោះ ហើយ គេអាចផ្ទេរបានយ៉ាងច្រើនបំផុតត្រឹមតែ០៩ក្រេឌីត ប៉ុណ្ណោះក្នុងចំណោម ៤៨ក្រេឌីត។
- សម្រាប់មុខវិជ្ជាសិក្សាណា ដែលគេស្វែងរកការសុំជំនួស ឬផ្ទេរក្រេឌីត អ្នកសិក្សាត្រូវតែដាក់ច្បាប់ចម្លងនៃកម្មវិធីសង្ខេបដោយភ្ជាប់ជាមួយនឹងព្រឹត្តិបត្រពិន្ទុ។
- ព័ត៌មានពាក់ព័ន្ធលម្អិត សូមទាក់ទងដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការនៃវិទ្យាស្ថានជាតិអប់រំ
- **សម្គាល់៖** និស្សិតអាចផ្ទេរក្រេឌីតបាន ប៉ុន្តែនៅរក្សាការបង់ថ្លៃសេវាសិក្សាដដែល (សម្រាប់តែនិស្សិតបង់ថ្លៃសិក្សា)។

## ១១. ការពិពណ៌នាអំពីមុខវិជ្ជាសិក្សា

**MEA 510 ក្រមសីលធម៌នៃភាពជាអ្នកដឹកនាំការងារអប់រំ**

មុខវិជ្ជានេះ គឺទាក់ទងនឹងសីលធម៌វិជ្ជាជីវៈក្នុងវិស័យអប់រំ។ អ្នកសិក្សា នឹងត្រូវបានលើកទឹកចិត្តឱ្យធ្វើការពិចារណា ថ្លឹងថ្លែងលើទិដ្ឋភាពវិជ្ជាជីវៈ និងបង្កើនការវាយតម្លៃផ្ទាល់ខ្លួនអំពីវិជ្ជាជីវៈអប់រំ។ គោលគំនិតចម្បងៗ ដែលនឹងត្រូវយកមកសិក្សាស្រាវជ្រាវ បង្ហាញ និងពិភាក្សា រួមមានក្រមសីលធម៌និងសារៈសំខាន់នៃក្រមសីលធម៌ បញ្ញត្តិបែបទស្សនវិជ្ជាដែលមានសារៈសំខាន់ក្នុងការសិក្សាក្រមសីលធម៌ ក្រមសីលធម៌វិជ្ជាជីវៈដែលនឹងត្រូវបំបែកទៅជាសីលធម៌សម្រាប់ (សិស្ស គ្រូបង្រៀន នាយកសាលារៀន និងអ្នកដឹកនាំការងារអប់រំ) និងសម្រង់គំនិតសំខាន់ៗ ពាក់ព័ន្ធនឹងក្រមសីលធម៌។ មុខវិជ្ជានេះ ក៏នឹងលើកយកមកបង្ហាញផងដែរនូវខ្លឹមសារមួយចំនួនពាក់ព័ន្ធនឹង ការដឹកនាំនិងការគ្រប់គ្រង អ្នកដឹកនាំនិងអ្នកគ្រប់គ្រង តួនាទីរបស់អ្នកដឹកនាំនិងអ្នកគ្រប់គ្រង គុណភាពនៃអ្នកដឹកនាំនិងអ្នកគ្រប់គ្រង ចរិកលក្ខណៈនៃភាពជាអ្នកដឹកនាំនិងគ្រប់គ្រង ភាពខុសគ្នារវាងការដឹកនាំនិងការគ្រប់គ្រង បុគ្គលិកលក្ខណៈទាំង១៤នៃអ្នកដឹកនាំនិងគ្រប់គ្រង និងទម្លាប់ទាំង៧យ៉ាងដែលអ្នកដឹកនាំការងារអប់រំប្រកាន់យក។

**MEA 511 ចិត្តវិទ្យាអប់រំ**

មូលដ្ឋានគ្រឹះនៃចិត្តវិទ្យា និងសង្គមវិទ្យាអប់រំត្រូវបានលើកយកមកសិក្សាស្រាវជ្រាវនៅក្នុងមុខវិជ្ជានេះដើម្បីអនុវត្តជាក់ស្តែងក្នុងវិស័យអប់រំ។ របៀបរៀន និងកត្តាផ្សេងៗដែលរំខានដល់ដំណើរការរៀនសូត្រនឹងត្រូវលើកយកមកពិភាក្សា។ គោលវិធីបង្រៀន ទស្សនវិជ្ជាអប់រំ និងបញ្ហាមួយចំនួនទៀតនឹងត្រូវបានលើកយកមកពិភាក្សា និងធ្វើការសិក្សា ស្រាវជ្រាវ។ អ្នកសិក្សាទាំងអស់នឹងត្រូវបានលើកទឹកចិត្តឱ្យពិភាក្សា និងបង្កើត

ទ្រឹស្តី អប់រំ ដោយខ្លួនគេផ្ទាល់។ មុខវិជ្ជានេះនឹងគ្របដណ្តប់ទៅលើការបង្កើត និងការអនុវត្តលើបញ្ញត្តិនៃទស្សនៈវិស័យសង្គមវិទ្យាដែលទាក់ទងទៅនឹងសង្គមមូបនីយកម្ម វប្បធម៌ រចនាសម្ព័ន្ធសង្គម និងការផ្លាស់ប្តូរនានា។

**MEA 512 សង្គមវិទ្យាអប់រំ**

មុខវិជ្ជានេះ ផ្តោតលើ សារៈសំខាន់នៃការអប់រំ បញ្ញត្តិនានានៃទ្រឹស្តីសង្គមវិទ្យា (យេនឌ័រនិងភេទ ទម្រង់រដ្ឋនិងរដ្ឋអំណាច ទម្រង់រដ្ឋាភិបាល សង្គមនិងអន្តរកម្មសង្គម សង្គមនីយកម្ម ការអប់រំសម្រាប់ទាំងអស់គ្នា ការអប់រំប្រែកដោយចីរភាព) តួនាទី នៃសង្គមវិទ្យាអប់រំក្នុងការអភិវឌ្ឍចំណេះដឹងពលរដ្ឋនានា និងសារប្រយោជន៍នៃការអប់រំ នៅក្នុងសង្គមនិងប្រព័ន្ធអប់រំនៅកម្ពុជាដោយផ្តោតលើខ្នាតគំរូរបស់សង្គមនិងអន្តរកម្មសង្គម។

**MEA 513 មូលដ្ឋានគ្រឹះនៃស្ថិតិក្នុងវិស័យអប់រំ**

មុខវិជ្ជានេះ នឹងរំឭកឡើងវិញនូវបញ្ញត្តិសំខាន់ៗនៃគណិតវិទ្យា ចំពោះស្ថិតិ ការជ្រើសរើសសំណាកគំរូ និងការប្រើប្រាស់កុំព្យូទ័រ។ ស្ថិតិពិពណ៌នា ការគណនាពិន្ទុ សំណាកគំរូ ប្រូបាប តម្រែតម្រង់លីនេអ៊ែ ណែនាំពីស្ថិតិសន្និដ្ឋាន និងតេស្តនៃសារៈសំខាន់ជាមូលដ្ឋាននឹងត្រូវពិភាក្សាក្នុងការសិក្សានេះ។

**MEA 514 វិធីសាស្ត្រស្រាវជ្រាវអប់រំ**

មុខវិជ្ជានេះ នឹងផ្តោតលើមូលដ្ឋានគ្រឹះវិធីសាស្ត្រស្រាវជ្រាវអប់រំ ដែលរួមមានការស្រាវជ្រាវ តាមបែបគុណភាពនិងបរិមាណ ការជ្រើសរើសសំណាកគំរូ ក្រមសីលធម៌ ឧបករណ៍ស្រាវជ្រាវ និងលទ្ធផលអាចយកជាការបាន។ គោលបំណងនេះ ដើម្បីបង្កើនសមត្ថភាពក្នុងការវិភាគត្រិះរិះពិចារណា និងដើម្បីពង្រឹងយុទ្ធសាស្ត្រឱ្យទទួលបានលទ្ធផលល្អប្រសើរក្នុងការអប់រំ។ ការកំណត់ និងការវាយតម្លៃទៅលើបញ្ហាស្រាវជ្រាវ ការប្រើប្រាស់ធនធានបណ្ណាល័យ ការប្រមូលទិន្នន័យ និងការសរសេរ របាយការណ៍ស្រាវជ្រាវ ជាចំណុចសំខាន់ក្នុងមុខវិជ្ជានេះ។ អ្នកសិក្សាអាចៈ

- កំណត់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណនិងគុណភាព ភាពស្រដៀងនិងខុសគ្នា និងការលើកភស្តុតាងមួយចំនួនមកប្រើប្រាស់នៅក្នុងទម្រង់នៃការស្រាវជ្រាវ
- វិភាគបញ្ហាស្រាវជ្រាវ និងទាញចេញនូវសំណួរស្រាវជ្រាវពាក់ព័ន្ធទៅនឹងការអប់រំសម្រាប់ធ្វើការសង្កេត
- ប្រើប្រាស់គោលការណ៍ស្រាវជ្រាវដើម្បីបង្កើតការចង្អុលបង្ហាញអំពីសំណួរស្រាវ

ស្រាវជ្រាវ
- កំណត់ និងជ្រើសរើសទ្រឹស្តី និងបញ្ញត្តិជាមូលដ្ឋានសម្រាប់បញ្ហាស្រាវជ្រាវ និង
- រៀបចំគម្រោងសិក្សាស្រាវជ្រាវ។

**MEA 520 បរិបទនៃសង្គមក្នុងការអប់រំ**

មុខវិជ្ជានេះអ្នកសិក្សានឹងត្រូវបានលើកទឹកចិត្តឱ្យពិនិត្យ និងពិភាក្សាលើបញ្ហាទាំងឡាយ ដែលទាក់ទងក្នុងវិស័យអប់រំបច្ចុប្បន្ន។ មុខវិជ្ជានេះ សិក្សាពីច្បាប់ស្តីពីការអប់រំ ច្បាប់រដ្ឋបាល ដែលទាក់ទិនទៅនឹងកិច្ចការអប់រំ។ ជាងនេះទៅទៀត ស្ថានភាព និងនិន្នាការអប់រំ បច្ចុប្បន្នដូចជាមុខវិជ្ជា គោលនយោបាយ ផ្នែកទ្រឹស្តីសង្គម និងការអនុវត្តជាក់ស្តែង នឹងត្រូវបានលើកយកមកសិក្សា។

**MEA 521 រដ្ឋបាលអប់រំ**

មុខវិជ្ជានេះ មានប្រធានបទដូចខាងក្រោម ត្រូវបានលើកយកមកពិភាក្សាៈ
- បញ្ញត្តិនៃការរៀបចំផែនការអប់រំ
- ការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ
- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា
- ការរៀបចំផែនប្រតិបត្តិប្រចាំឆ្នាំ
- ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀននិងផែនប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀន

**MEA 522 បច្ចេកវិទ្យាក្នុងការគ្រប់គ្រង និងការរៀននិងបង្រៀន**

ការបង្កើតបរិយាកាសសិក្សា និងការបង្រៀនជោគជ័យសម្រាប់សិស្ស និងបុគ្គលិក គឺជាប្រធានបទយ៉ាងសំខាន់នៅក្នុងមុខវិជ្ជានេះ។ មុខវិជ្ជានេះត្រូវបានរៀបចំឡើងដើម្បីត្រួតពិនិត្យលើការគ្រប់គ្រង ការបង្រៀន បច្ចេកទេសគ្រប់គ្រង និងជំនាញផ្សេងៗទៀត ដែលចាំបាច់ក្នុងការចាត់ចែង និងវាយតម្លៃកម្មវិធីបណ្តុះបណ្តាល។ វាផ្តោតផងដែរលើវិធីសាស្ត្រសំខាន់ៗនៃការគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍកម្មវិធីសិក្សា ការលើកកម្ពស់ការបង្រៀនតាមរយៈការប្រមូលទិន្នន័យ ការវាយតម្លៃជាដំណាក់ ការវាយតម្លៃបញ្ចប់លើស្តង់ដានៃការបង្រៀន និងការអភិវឌ្ឍបុគ្គលិក។ គេរំពឹងថាសិក្ខាកាមនឹងមានទំនាក់ទំនងល្អជាមួយបុគ្គលិក និងសហគមន៍ព្រោះពួកគេជាអ្នកបង្កើតស្តង់ដារសិស្ស វាយតម្លៃសិស្សនិងជួយបុគ្គលិកក្នុងការវាយតម្លៃការសិក្សា ដឹកនាំការបង្រៀនឱ្យមាន

ប្រសិទ្ធភាព និងលើកកម្ពស់បរិយាកាសសាលារៀនមួយសម្រាប់ការសិក្សា។ វគ្គនេះលើកឡើងអំពីសារៈសំខាន់នៃការប្រតិបត្តិការកុំព្យូទ័រ ការបញ្ចូលបច្ចេកវិទ្យាកុំព្យូទ័រក្នុងបរិយាកាសសិក្សា ទ្រឹស្តីនៃការរៀន ឬគម្រោងធ្វើបទបង្ហាញដោយប្រើបច្ចេកវិទ្យា និងការប្រើប្រាស់បទបង្ហាញ និងកម្មវិធីកុំព្យូទ័រពាក់ព័ន្ធ។ ក្រោយបញ្ចប់មុខវិជ្ជានេះដោយជោគជ័យ អ្នកសិក្សានឹងអាចៈ

- បង្កើនចំណេះដឹងផ្នែកប្រតិបត្តិការកុំព្យូទ័រ តបណ្តាញ អ៊ីនធឺណែតនិងគេហទំព័រ
- ប្រើប្រាស់បច្ចេកវិទ្យាពាក់ព័ន្ធក្នុងការបង្កើតសម្ភារឧបទ្ទេសសិក្សាផ្សេងៗ
- ពណ៌នាអំពីវិធីសាស្ត្របង្រៀនថ្មីៗ ការសិក្សាស្រាវជ្រាវ និងការវាយតម្លៃការអនុវត្តដែលមានទំនាក់ទំនងទៅនឹងការប្រើប្រាស់កុំព្យូទ័រ និងធនធានបច្ចេកវិទ្យាក្នុងកម្មវិធីសិក្សា
- ពិភាក្សា និងវិភាគបញ្ហានានា ដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់កុំព្យូទ័រក្នុងវិស័យអប់រំ រួមមានបញ្ហាសុវត្ថិភាព សមភាព កម្មសិទ្ធិបញ្ញា និងក្រមសីលធម៌វិជ្ជាជីវៈនៃការប្រើប្រាស់អ៊ីនធឺណែតក្នុងថ្នាក់រៀន។ ការបង្កើតកម្មវិធីប្រើប្រាស់បច្ចេកវិទ្យានេះមានឡើងអាស្រ័យទៅលើស្ថានភាពបណ្តុះបណ្តាលជាក់ស្តែង
- រៀបចំតាក់តែង ឬអភិវឌ្ឍកម្មវិធីដោយប្រើបច្ចេកវិទ្យាសម្រាប់ធ្វើបទបង្ហាញ
- ការរៀន និងបង្រៀនពីចម្ងាយ។

**MEA 523 ការអភិវឌ្ឍកម្មវិធីសិក្សា**

ការអភិវឌ្ឍកម្មវិធីសិក្សានៅកម្រិតបឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សាត្រូវបានលើកយកមកពិភាក្សានៅក្នុងមុខវិជ្ជានេះ។ វាផ្តោតសំខាន់លើការធ្វើផែនការការរៀបចំកម្មវិធីសិក្សា ក៏ដូចជាការអភិវឌ្ឍមុខវិជ្ជានីមួយៗ និងទំនាក់ទំនងរបស់វាទៅនឹងបេសកកម្ម កម្មវត្ថុ និងលទ្ធផល។ មុខវិជ្ជានេះនឹងៈ

(i) វិភាគបញ្ហាពីនិន្នាការនានាសម្រាប់រៀបចំ និងធ្វើផែនការកម្មវិធី

(ii) វាយតម្លៃផលប៉ះពាល់នៃភ្នាក់ងារត្រួតពិនិត្យ និងផ្តល់គុណភាពលើការរៀបចំកម្មវិធីសិក្សា

(iii) ពិពណ៌នាពីសារៈសំខាន់នៃទ្រឹស្តីក្នុងការធ្វើផែនការ និងការរៀបចំកម្មវិធីសិក្សា

(iv) វិភាគទៅលើជំនឿ និងគុណតម្លៃនៃការអប់រំជាមូលដ្ឋានព្រមទាំងផលប៉ះពាល់

(v) ពិពណ៌នាទ្រឹស្តីនៃការសិក្សាផ្សេងៗ និងការជះឥទ្ធិពលរបស់វាលើការធ្វើផែនការ

និងការរៀបចំកម្មវិធីសិក្សា។

**MEA 524 ការគ្រប់គ្រងធនធានថវិកា និងសម្ភាររូបវន្តនៃការអប់រំ**

លំនាំនៃការរៀបចំ ការវិភាគ និងការត្រួតពិនិត្យថវិកា គឺមានសារៈសំខាន់ណាស់សម្រាប់ធ្វើចរាចរហិរញ្ញវត្ថុរបស់ស្ថាប័ន អង្គភាព ឬសេវាកម្មណាមួយ។ បញ្ញត្តិនៃការធ្វើរបាយការណ៍ហិរញ្ញវត្ថុក៏ដូចជាគោលការណ៍សេដ្ឋកិច្ចជាមូលដ្ឋាន ត្រូវបានគេយកមកអនុវត្ត។ មុខវិជ្ជានេះនឹងផ្តោតសំខាន់លើ៖

(i) ការរៀបចំ និងត្រួតពិនិត្យថវិកា ដូចជាការវិភាគលើការប្រែប្រួលថវិកា និងយុទ្ធសាស្ត្រនានាសម្រាប់ដោះស្រាយនូវការប្រែប្រួលទាំងនោះ។ បង្កើតយុទ្ធសាស្ត្រសម្រាប់ការត្រួតពិនិត្យថវិកា និងការបង្កើតថវិកាជាសមាសភាគ មួយនៃការធ្វើផែនការអាជីវកម្ម។

(ii) ការវិភាគ ការអនុវត្តហិរញ្ញវត្ថុ មានដូចជា វាយតម្លៃការអនុវត្តហិរញ្ញវត្ថុរបស់ស្ថាប័ន ឬការធ្វើអាជីវកម្មណាមួយដោយប្រើប្រាស់ តារាងតុល្យភាព របាយការណ៍ចំណូលចំណាយ របាយការណ៍លំហូរសាច់ប្រាក់ និងសមាមាត្រហិរញ្ញវត្ថុ។

**MEA 525 ការគ្រប់គ្រងធនធានមនុស្សក្នុងវិស័យអប់រំ**

មុខវិជ្ជានេះពិនិត្យពីតួនាទីរបស់អ្នកជំនាញការធនធានមនុស្ស ដែលជាដៃគូរយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងស្ថាប័ន ឬអង្គភាពនានាក្នុងពេលបច្ចុប្បន្ន។ មុខងារសំខាន់ៗដូចជា៖ ការតែងតាំង ការជ្រើសរើស ការអភិវឌ្ឍ ការវាយតម្លៃ សំណងឬការប៉ះប៉ូវ និងទំនាក់ទំនងពលកម្មត្រូវបានត្រួតពិនិត្យ។ ផលប៉ះពាល់នានានៃច្បាប់ និងបរិយាកាសសកលត្រូវបានវាយតម្លៃ ហើយបញ្ហាថ្មីៗដូចជា៖ ការបណ្តុះបណ្តាលផ្សេងៗ ការបំពារបំពានផ្លូវភេទ និងការកើនឡើងនៃប្រាក់ចំណូលត្រូវបានវិភាគ។ ជម្រើសរបស់នយោជកក្នុងការអនុវត្តដ៏ល្អបំផុតត្រូវបានលើកមកពិភាក្សា។ លើសពីនេះទៅទៀត មុខវិជ្ជានេះក្តោបលើនីតិកម្ម ការវិភាគការងារ និងការរៀបចំផែនការធនធានមនុស្ស ដោយផ្តោតលើការផ្តល់បុគ្គលិកឱ្យស្ថាប័ន ឬអង្គភាពមួយឱ្យត្រូវនឹងប្រភេទ និងចំនួននៃនយោជិកដែលខ្លួនត្រូវការនៅពេលណាមួយ។ ប្រធានបទនានាអាចរួមបញ្ចូលការណែនាំបុគ្គលិកថ្មី ការបណ្តុះបណ្តាលអន្តរកម្មដំបូង ការអប់រំសម្រាប់អ្នកប្រតិបត្តិកម្រិតខ្ពស់ កម្មវិធីការអភិវឌ្ឍអាជីពដើម្បីបង្កើនការងារជាក្រុម ការអភិវឌ្ឍស្ថាប័ន ឬអង្គភាពក្នុងការឆ្លើយតបទៅនឹងការផ្លាស់ប្តូរសំណង និងដំណើរការលើកិច្ចព្រមព្រៀងតម្

លែ។

**MEA 526 ការតាមដាន និងការវាយតម្លៃការអប់រំ**

មុខវិជ្ជានេះមានគោលបំណងត្រួតពិនិត្យទៅលើការបង្រៀន បច្ចេកទេសចាត់ចែង និងជំនាញផ្សេងៗទៀតដែលចាំបាច់ក្នុងការគ្រប់គ្រង និងវាយតម្លៃកម្មវិធីសិក្សា។ វាក៏ផ្តោតផងដែរទៅលើការតាមដាន និងវាយតម្លៃពីរបៀបគ្រប់គ្រងបុគ្គលិក ការអភិវឌ្ឍកម្មវិធីសិក្សា ការកែលម្អការបង្រៀនតាមរយៈលទ្ធផលនៃការសិក្សា ការវាយតម្លៃជាដំណាក់ៗ ការវាយតម្លៃចុងក្រោយតាមស្តង់ដា និងការអភិវឌ្ឍបុគ្គលិក។

អ្នកសិក្សាត្រូវបានរំពឹងទុកថាអាចបង្កើតទំនាក់ទំនងល្អជាមួយបុគ្គលិក និងសហគមដូចជាការអភិវឌ្ឍយន្តការវាយតម្លៃសិស្ស ជួយបុគ្គលិកក្នុងការវាយតម្លៃការសិក្សា បង្កើនគុណភាពបង្រៀនឱ្យមានប្រសិទ្ធភាព និងជំរុញឱ្យមានបរិយាកាសសិក្សាល្អក្នុងសាលារៀន។

**MEA 530 ការអប់រំនៅកម្ពុជា**

មុខវិជ្ជានេះ ផ្តោតសំខាន់លើការពិភាក្សាអំពីរចនាសម្ព័ន្ធ និងការគ្រប់គ្រងវិស័យអប់រំនៅចំណោះទូទៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ អ្នកសិក្សាត្រូវលើកទឹកចិត្តដើម្បីរិះរកឯកសារដែលមានស្រាប់ និងសៀវភៅសិក្សាលើមាតិកា ដែលទាក់ទងនឹងកម្មវិធីសិក្សាបច្ចុប្បន្ន រួមមាន៖

- គោលនយោបាយ
- វិធីសាស្ត្របង្រៀន
- ការត្រួតពិនិត្យ
- ការចាត់ចែង ការវាយតម្លៃ និងអភិបាលកិច្ចជាប្រចាំ។

វិសាលភាពនៃខ្លឹមសារមេរៀននេះ ត្រូវតែកំណត់ឱ្យបានច្បាស់លាស់ស្តីពីអភិបាលកិច្ចល្អនៃគ្រប់ភូមិសិក្សា និងគ្រឹះស្ថានឧត្តមសិក្សាគ្រប់កម្រិតរួមមាន៖ មតេយ្យ បឋមសិក្សា មធ្យមសិក្សាបឋមភូមិ មធ្យមសិក្សាទុតិយភូមិ ថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។

មុខវិជ្ជានេះ ជាមគ្គុទ្ទេសក៍ដ៏សំខាន់សម្រាប់កំណត់លក្ខណៈវិនិច្ឆ័យពីដំណើរការទទួលស្គាល់គុណភាពអប់រំ ដោយគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

**MEA 531 ការគ្រប់គ្រងសាលារៀន និងការគ្រប់គ្រងការបំពេញការងារក្នុងសាលា**

មុខវិជ្ជានេះផ្តោតសំខាន់ទៅលើអ្នកគ្រប់គ្រងសាលារៀន និងអ្នកដែលទទួលបន្ទុកការគ្រប់គ្រងផ្សេងៗទៀត។ គោលបំណងសំខាន់ គឺពង្រឹងការយល់ដឹងឱ្យស៊ីជម្រៅអំពីទស្សនវិស័យនៃការគ្រប់គ្រង តាមរយៈការបំពាក់នូវជំនាញច្បាស់លាស់ និងជំរុញពួកគេឱ្យបង្កើតផែនការគ្រប់គ្រងដោយខ្លួនឯងសម្រាប់ឆ្នាំសិក្សានីមួយៗ។ អ្នកសិក្សាទាំងអស់ នឹងបញ្ចេញនូវជំនាញនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរួមមាន ទម្លាប់ក្នុងការអនុវត្ត ការបង្កើតយន្តការក្នុងការវាយតម្លៃ បង្កើតផែនការវាយតម្លៃប្រចាំឆ្នាំដោយប្រើកម្រងព័ត៌មានសម្រាប់ប្រមូលចងក្រងភស្តុតាងសកម្មភាពអនុវត្ត ផ្តល់វគ្គបំប៉ន និងបង្កើតផែនការអនុវត្តនៅពេលអនាគត។

MEA 532 **ការសិក្សាជំនាញសរសេរភាសាអង់គ្លេសកម្រិតខ្ពស់**

មុខវិជ្ជានេះ មានគោលបំណងលើកកម្ពស់សមត្ថភាពក្នុងការសរសេរជាភាសាអង់គ្លេសចំពោះអ្នកសិក្សាទាំងឡាយ ដែលមានឧបនិស្ស័យក្នុងការសរសេរអត្ថបទស្រាវជ្រាវផ្សេងៗ។ វាចាប់ផ្តើមពីការរំលឹកមូលដ្ឋានគ្រឹះនៃវេយ្យាករណ៍ និងជំនាញក្នុងការសរសេរ។ វាក៏គ្របដណ្តប់ទៅលើគន្លឹះជាច្រើនផងដែរ ក្នុងការរៀបចំកម្រងសំណួរ ការប្រមូល និងវិភាគទិន្នន័យ និងរបៀបនៃការសរសេរនិក្ខេបបទ។

MEA 533 **ការគ្រប់គ្រងអប់រំនៅគ្រឹះស្ថានសិក្សាឯកជន**

មុខវិជ្ជានេះ ផ្តោតទៅលើការបរិយាយពីការបង្កើតការគ្រប់គ្រងជាប្រព័ន្ធ និងអភិបាលកិច្ចក៏ដូចជាយន្តការនៃការគ្រប់គ្រងសាលា និងគ្រឹះស្ថានសិក្សាឯកជន។ អ្នកសិក្សាត្រូវបានជំរុញឱ្យពិភាក្សាលើប្រធានបទដែលទាក់ទងទៅនឹងសាលាឯកជន រួមមានរចនាសម្ព័ន្ធ មនុស្ស សិទ្ធិអំណាច គោលនយោបាយ ប្រសិទ្ធភាព គុណភាព សេចក្តីសម្រេច ទំនាក់ទំនង ភាពជាអ្នកដឹកនាំ និងបរិយាកាសវប្បធម៌ក្នុង និងក្រៅសាលា។

MEA 534 **ការគ្រប់គ្រងនិងដឹកនាំភាពផ្លាស់ប្តូរ ប្រសិទ្ធភាពនៃការប្រើប្រាស់ធនធាន និងការពង្រឹងបណ្តាញ**

មុខវិជ្ជានេះ នឹងផ្តោលលើ៖

- ពង្រឹងទៅលើការគ្រប់គ្រង និងធ្វើការផ្លាស់ប្តូរពីភាពអសកម្ម ទៅភាពសកម្មនៃការគ្រប់គ្រងនៅតាមសាលាធនធាន និងសាលាបណ្តាញ
- បណ្តុះគំនិតថ្មីទៅដល់នាយក/នាយិកា នាយករង/នាយិការង និងប្រធានក្រុមបច្ចេកទេសក្នុងការដោះស្រាយបញ្ហាប្រឈមដែលបានជួបប្រទះកន្លងមក

- បង្កើតផែនការថ្មីសម្រាប់ការគ្រប់គ្រងតាមរយៈបទពិសោធន៍នូវភាពជោគជ័យ ដែលទទួលបានពីសាលាបណ្ដាញ និងសាលាធនធាន
- បង្កើតផែនការគំនិត កំនត់បញ្ហា បង្កើតជម្រើសដោះស្រាយ បង្កើតដំណោះស្រាយប្រកបដោយប្រសិទ្ធភាព និងនិរន្តភាពនៃការផ្លាស់ប្តូរការគ្រប់គ្រងសាលាធនធាន និងសាលាបណ្ដាញ។

MEA 599 **និក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់**

អ្នកសិក្សា ត្រូវយល់ដឹងអំពីព័ត៌មានដូចខាងក្រោម មុនពេលសរសេរនិក្ខេបបទ៖

- បានរៀនចប់មុខវិជ្ជា និងទទួលបានក្រេឌីតចំនួន៤២ ជាមួយនឹងមធ្យមភាគពិន្ទុ (GPA) យ៉ាងតិច ២.៥០
- ប្រធានបទនៃនិក្ខេបបទ និងគោលគំនិតសំខាន់ៗសម្រាប់គម្រោងសិក្សាស្រាវជ្រាវ ទទួលបានការឯកភាពពីសាស្ត្រាចារ្យដឹកនាំបង្គោល និងរង (សូមអានសៀវភៅព័ត៌មានអំពីថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់)
- អ្នកសិក្សាម្នាក់ៗត្រូវធានាថា និក្ខេបបទរបស់ខ្លួន ត្រូវសរសេរឡើងជាបន្តបន្ទាប់ ជាមួយការណែនាំ និងកែលម្អពីសាស្ត្រាចារ្យត្រួតពិនិត្យ
- សេចក្ដីព្រាងនៃនិក្ខេបបទ ត្រូវតែដាក់ជូនគណៈកម្មការកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដើម្បីធ្វើការវាយតម្លៃ រិះគន់ និងលើកជាសំណូមពរសម្រាប់កែលម្អ ក្រោយទទួលបានការឯកភាពពីគណៈកម្មការវាយតម្លៃនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងការការពារ ឬការធ្វើបទបង្ហាញនិក្ខេបបទនោះនឹងត្រូវបានរៀបចំឡើងសម្រាប់អ្នកសិក្សាម្នាក់ៗ។

## ១២. ការវាយតម្លៃការបណ្ដុះបណ្ដាល

ការវាយតម្លៃនៃការបណ្ដុះបណ្ដាល គឺជាចំណុចសំខាន់ក្នុងការវាស់ស្ទង់ពីអ្វីដែលអ្នកសិក្សាអាចទទួលបានពីការបណ្ដុះបណ្ដាលដោយធៀបទៅនឹងវត្ថុបំណងនៃមេរៀននីមួយៗ។ វិធីសាស្ត្រវាយតម្លៃទាំងនោះ រួមមាន៖

- សំណួរផ្ទាល់មាត់
- កិច្ចការផ្ទះ
- ការធ្វើកិច្ចការជាក្រុម
- ការឡើងធ្វើបទបង្ហាញ

- ការសួរសំណួរ (ដោយប្រើប្រាស់ប្រភេទផ្សេងៗនៃសំណួរ)
- ការពិភាក្សា
- ការរៀបចំគម្រោងស្រាវជ្រាវ
- ការប្រឡងពាក់កណ្ដាលឆមាស និង
- ការប្រឡងបញ្ចប់

## ឯកសារយោង

វិទ្យាស្ថានជាតិអប់រំ (២០១៥) *បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

វិទ្យាស្ថានជាតិអប់រំ (២០១៨) *ផែនការយុទ្ធសាស្ត្រវិទ្យាស្ថានជាតិអប់រំ២០១៩-២០២៣* ភ្នំពេញ វិទ្យាស្ថានជាតិអប់រំ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល នីតិកាលទី៦ នៃរដ្ឋសភា ខែកញ្ញា ឆ្នាំ ២០១៨។

ក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា ខែមីនា ឆ្នាំ២០១៤។

National Institute of Education international. (2020). *Report on the Review of NIE-C's PRESETT and INSETT Curriculums*. Singapore: National Institute of Education International.